ក្រសួងយុត្តិធម៌

លេខ : ១៨៤ អយ.ប្រក/២០

# ប្រកាស
# ស្តីពី
# ទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីបែបបទនិងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គល ឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ស្របតាមមាត្រា១៣ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយ



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

អាវុធមហាប្រល័យ និងមាត្រា៨ នៃអនុក្រឹត្យលេខ១៦១ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ប្រការ ២.-**

យោងតាមស្មារតីនៃមាត្រា១១ នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ សំដៅដល់បុគ្គលឬអង្គភាពទាំងឡាយណាដែលមិនមានកំណត់ចាប់ពីចំណុច ក ដល់ចំណុច ណ ដូចខាងក្រោមនេះ៖

ក- ធនាគារ រួមទាំងសាខារបស់ធនាគារបរទេស។

ខ- គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនជើងសារមូលបត្រនិងក្រុមហ៊ុនធានារ៉ាប់រង។

គ- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ឃ- សហករណ៍ឥណទាន។

ង- ក្រុមហ៊ុនភតិសន្យា មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ។

ច- អាជីវកម្មប្តូរប្រាក់។

ឆ- សេវាផ្ទេរប្រាក់។

ជ- បរធនបាលកិច្ច។

ឈ- ភ្នាក់ងារ ក្រុមហ៊ុន អ្នកអភិវឌ្ឍន៍អចលនទ្រព្យ អគារ និងដីធ្លី។

ញ- ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ។

ដ- ការិយាល័យប្រៃសណីយ៍ ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់។

ឋ- មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះរៀបចំឬធ្វើប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួន។

ឌ- កាស៊ីណូនិងគ្រឹះស្ថានល្បែងភ្នាល់ផ្សេងៗ។

ឍ- អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមូលនិធិធ្វើសកម្មភាពអាជីវកម្មនិងរៃអង្គាសមូលនិធិ។

ណ- បុគ្គលឬអង្គភាពផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ប្រការ ៣.-**

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ ត្រូវរាយការណ៍ទៅក្រសួងយុត្តិធម៌អំពីការបង្កកទ្រព្យសម្បត្តិតាមដីកាសម្រេចរបស់តុលាការ និងអំពីការប៉ុនប៉ងទាំងឡាយក្នុងការធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកនោះ។ របាយការណ៍នេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៣(បី)ថ្ងៃ គិតពីថ្ងៃដែលខ្លួនបានបង្កក

ទ្រព្យសម្បត្តិនោះ ឬគិតពីថ្ងៃនៃការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកនោះ និងតាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងព្រហ្មទណ្ឌ គ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ និងបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៥៩៥

ថ្ងៃ ចន្ទ ៨ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៤ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ១៨៤ កយ.ប្រក/២០
ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងយុត្តិធម៌

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

(*ចំពោះរូបវន្តបុគ្គល៖* ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............. កើតនៅថ្ងៃទី..... ខែ....... ឆ្នាំ........ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះលេខ......... ផ្លូវ.......... ឃុំ/សង្កាត់.............. ស្រុក/ខណ្ឌ............. រាជធានី/ខេត្ត........... កាន់អត្តសញ្ញាណប័ណ្ណលេខ.......... ចុះថ្ងៃទី........ ខែ....... ឆ្នាំ....... មានទូរស័ព្ទលេខ.............. )

(*ចំពោះនីតិបុគ្គល៖* ក្រុមហ៊ុន/សមាគម/អង្គការ............ ចុះបញ្ជីលេខ............ នៅ............ ថ្ងៃទី..... ខែ....... ឆ្នាំ....... មានទីស្នាក់ការ នៅផ្ទះលេខ....... ផ្លូវ.............. ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ............. រាជធានី/ខេត្ត.......... មានទូរស័ព្ទលេខ.............. )

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីការបង្កកទ្រព្យសម្បត្តិរបស់............. (ឈ្មោះបុគ្គលឬអង្គភាពដែលជាកម្មវត្ថុនៃការបង្កក)។

**យោង** ៖ - ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

- អនុក្រឹត្យលេខ១៦១ អនក្រ.បក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ប្រកាសលេខ ១៨៤ កយ.ប្រក/២០ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងយុត្តិធម៌ ស្តីពីទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍
- ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ............ ចុះថ្ងៃទី......... ខែ.............. ឆ្នាំ.............. របស់...........។

| ល.រ | ឈ្មោះបុគ្គលឬអង្គភាពដែលជាកម្មវត្ថុនៃការបង្កក | ប្រភេទទ្រព្យសម្បត្តិដែលត្រូវបានបង្កក | អត្តសញ្ញាណនៃទ្រព្យសម្បត្តិដែលត្រូវបានបង្កក | ស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវបានបង្កក[១] | តម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិដែលត្រូវបានបង្កក | ការថែរក្សាទ្រព្យសម្បត្តិដែលត្រូវបានបង្កក | ការប៉ុនប៉ងធ្វើប្រតិបត្តិការលើទ្រព្យសម្បត្តិដែលត្រូវបានបង្កក[២] (ប្រសិនបើមាន) | កាលបរិច្ឆេទនៃការបង្កក |
|---|---|---|---|---|---|---|---|---|

[១] រៀបរាប់អំពីស្ថានភាពគតិយុត្តនៃទ្រព្យសម្បត្តិរួមមានជាអាទិ៍ សិទ្ធិកាន់កាប់លើទ្រព្យ(កម្មសិទ្ធិ/ជួល/ខ្ចី...) សិទ្ធិប្រាតិភោគលើទ្រព្យសម្បត្តិ(ហ៊ីប៉ូតែក/បញ្ចាំ/សិទ្ធិជួលអចិន្ត្រៃយ៍...)

[២] រៀបរាប់ជាអាទិ៍ អំពីប្រភេទនៃប្រតិបត្តិការ អត្តសញ្ញាណនៃបុគ្គលដែលប៉ុនប៉ងធ្វើប្រតិបត្តិការ កាលបរិច្ឆេទនៃការប៉ុនប៉ង

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃ.................. ខែ.................. ឆ្នាំ.................. ស័ក ព.ស.២៥..................

ធ្វើនៅ.............. ថ្ងៃទី.............. ខែ.................. ឆ្នាំ២០..................

**បុគ្គល/ប្រធានអង្គភាពក្រៅពីបុគ្គលរាយការណ៍**

*(ហត្ថលេខា/ស្នាមមេដៃ ឬហត្ថលេខា និងត្រា)*

*(ឈ្មោះ)*